ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

**COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)**

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,

Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

**គណៈកម្មាធិការនាយក**

**BOARD OF DIRECTORS**

លោក **ធុន សារាយ**
**Mr. THUN Saray**
ជាប្រធានគណៈកម្មាធិការនាយក និងជាប្រធានសមាគម **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
ជាអនុប្រធានគណៈកម្មាធិការនាយក និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហិរញ្ញិក និងជានាយក **CCPCR**

លោក **យៀង វណ្ណា**
**Mr. YEANG Vanna**
ប្រធាន **KKKHRA**

លោក **ជីវ យូម៉េង**
**Mr. CHIV You Meng**
ប្រធាន **KYA**

លោកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep**
នាយិកា **LAC**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
ប្រធាន **PDP Center**

លោក **ទូច ទុម្ព**
**Mr. TOUCH Tum**
នាយក **VIGILANCE**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

កញ្ញា **សយ សារា វឌ្ឍនី**
**Ms. SAY Sara Vathany**
នាយិកា **CWCC**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**
**ឥស្សរជន**

លោក **សឺន សែត**
**Mr. SEN Set**
**ឥស្សរជន**

ស.ប្រ.ក.៣/លេខ ០៤/០៨ គ.ប.ស.យ/អ.ក

# របាយការណ៍សង្ខេបបឋមលើកទី ៣

# ស្តីពី

# ការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត និង ស្ថានភាពដំណាក់កាលត្រៀមការបោះឆ្នោតឆ្នាំ ២០០៨

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨*

នៅក្នុងដំណាក់កាលនៃដំណើរការចុះបញ្ជីឈ្មោះបេក្ខជន និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត[១] សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ នេះ មានគណបក្សនយោបាយចំនួនតែ **១២** ប៉ុណ្ណោះ[២] ក្នុងចំណោមគណបក្សនយោបាយប្រមាណជាង ៥០ ដែលបានចុះឈ្មោះនៅក្រសួងមហាផ្ទៃ បានយកសំណុំបែបបទទៅចុះបញ្ជីនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងការធ្លាក់ចុះចំនួនបេក្ខនារីមកនៅត្រឹម ១៤%។ ចំនួនគណបក្សនយោបាយ មានការធ្លាក់ចុះ**ជិតពីរដង** បើប្រៀបធៀបជាមួយនឹងការបោះឆ្នោតឆ្នាំ ២០០៣ ដែលមានគណបក្សឈរឈ្មោះចំនួន ២៣ (ប្រហាក់ប្រហែលនឹងឆ្នាំ ១៩៩៣ ដែលមាន ២០ គណបក្សចូលរួមប្រកួតប្រជែងការបោះឆ្នោត) និងធ្លាក់ចុះ**ជាងបីដង** បើប្រៀបធៀបជាមួយនឹងការបោះឆ្នោតឆ្នាំ ១៩៩៨ ដែលមានគណបក្សឈរឈ្មោះរហូតដល់ចំនួន ៣៩។ ការធ្លាក់ចុះនៃការចូលរួមរបស់គណបក្សនយោបាយក្នុងដំណើរការបោះឆ្នោតនេះ ជាសញ្ញាមិនល្អសម្រាប់ដំណើរការបោះឆ្នោតតាមប្រព័ន្ធបោះឆ្នោតសមាមាត្រតាមរយៈបញ្ជីគណបក្ស។ ប្រព័ន្ធនេះតម្រូវឱ្យគណបក្សច្រើនចូលរួមពហុគណបក្ស ព្រោះថាប្រព័ន្ធសមាមាត្រមិនបានលើកទឹកចិត្តពហុឯកត្តនាមនោះទេ។

រហូតមកដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨នេះ មានគណបក្សចំនួន ១១ ដែលត្រូវបាន គ.ជ.ប យល់ព្រមចុះបញ្ជីជាផ្លូវការដែលក្នុងនោះមានគណបក្សនយោបាយខ្លះដែលបេក្ខជនមួយចំនួនរបស់ខ្លួន ត្រូវបានបដិសេធ។ **មានគណបក្សចំនួន ១ គឺគណបក្ស សង្គមខ្មែរនិយម ត្រូវបាន គ.ជ.ប បដិសេធ។** មានភាព

[១] ចាប់ពីថ្ងៃទី២៨ ខែមេសា ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨

[២] ក្នុងចំណោមគណបក្សទាំង ១២ នោះ មានគណបក្សចំនួន ៧ ជាគណបក្សថ្មី (សូមមើលលំអិតនៅចំណុច គ)។ គណបក្សទាំង ១២ មាន: គណបក្សប្រជាជនកម្ពុជា គណបក្សសង្គមខ្មែរនិមយ គណបក្សហង្សដាវ៉ាចលនាប្រជាធិបតេយ្យ គណបក្សនរោត្តម រណប្ញទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសិទ្ធិមនុស្ស គណបក្សសង្គមយុត្តិធមិ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សសម រង្ស៊ី គណបក្សខ្មែរឈប់ក្រ គណបក្សប្រជាធិបតេយ្យខ្មែរ និងគណបក្សខ្មែរសាធារណរដ្ឋ។

មិនប្រក្រតីខ្លះទាក់ទិននឹងការបដិសេធ ដែលបណ្តាលមកពីការបាត់ឈ្មោះរបស់បេក្ខជនពីបញ្ជីបោះឆ្នោត។ យ៉ាងហោចណាស់មានបណ្តឹងគណបក្សមួយបានដាក់ទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ខុមហ្វ្រែលបន្តសង្កេតលើដំណើរការទទួលពាក្យ និងការដោះស្រាយបណ្តឹងនោះ។

ក្នុងអំឡុងពីខែមេសា ដល់ ឧសភា មានករណីឃាតកម្ម **អំពើហិង្សាទៅលើសកម្មជនគណបក្សនយោបាយ** និង **ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ** (ស្លាកសញ្ញា) គណបក្សនយោបាយកើតមាន និងកើនឡើង បើធៀបនឹងខែមុនៗ។[៣] ការផ្សព្វផ្សាយជាចំហ[៤] ក្នុង**ការអូសទាញបេក្ខជន និងសមាជិកគណបក្សនយោបាយផ្សេងទៀតដើម្បីចុះចូលជាមួយនឹងគណបក្សប្រជាជនកម្ពុជា ដែលមានបំណងធ្វើឱ្យប៉ះពាល់ដល់ការរៀបចំបញ្ជីបេក្ខជនគណបក្សផ្សេងទៀត**។ ការអូសទាញបែបនេះអាចបង្កើតជាទម្លាប់មិនល្អ និងរំលោភក្រមសីលធម៌របស់គណបក្សនយោបាយ។

## គ. ភាពមិនប្រក្រតីនៃដំណើរការចុះបញ្ជីគណបក្សនយោបាយ

តាមមាត្រា ៣៨ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានតម្រូវឱ្យបេក្ខជនដែលឈរឈ្មោះបោះឆ្នោតត្រូវទៅបញ្ជាក់អំពីការបោះឆ្នោតដោយអាជ្ញាធរ ឃុំ/សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត។ ចំណុចនេះជាបញ្ហាមួយ ក្នុងចំណោមបញ្ហាជាច្រើនដែលបានបង្កការលំបាកយ៉ាងខ្លាំងទៅលើការបំពេញសំណុំបែបបទជាបេក្ខជន។ មានបេក្ខជនមួយចំនួនមកពីគណបក្សនយោបាយយ៉ាងហោចណាស់ចំនួន ៥ បានលើកឡើងនូវការលំបាកដែលពួកគេបានជួបប្រទះ ដូចជាៈ មេឃុំ/ចៅសង្កាត់ មន្ត្រីក្រុមប្រឹក្សាឃុំ/សង្កាត់ មានការរើសអើង ពន្យារពេលក្នុងការបញ្ជាក់ឈ្មោះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការសង្កេតពុំឃើញមានការខកខានដោយសារបញ្ហានេះ និងពុំមានបណ្តឹងអំពីករណីនេះទៅ គ.ជ.ប ទេ។

មានភាពមិនប្រក្រតី ស្តីពីការបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោត ដោយអាជ្ញាធរឃុំ/សង្កាត់ ដែលសាមីខ្លួនបេក្ខជនបានចុះឈ្មោះបោះឆ្នោត និងការបដិសេធរបស់ គ.ជ.ប ទៅលើបេក្ខជន ថាមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។ បញ្ហាទាំងនេះមិនមានកើតឡើង ឬមានតិចតួចបំផុតនៅក្នុងការចុះឈ្មោះបញ្ជីគណបក្សក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិមុនៗនោះទេ។ គ.ជ.ប មិនបានសម្រេចលើពាក្យសុំចុះឈ្មោះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមួយចំនួន ដោយមូលហេតុ គ.ជ.ប បានរកឃើញថា នៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ បេក្ខជនមួយចំនួននៅក្នុងបញ្ជីគណបក្សនោះ មិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បើទោះបីអាជ្ញាធរឃុំ/សង្កាត់ បានចេញសេចក្តីបញ្ជាក់ឱ្យសាមីខ្លួនបេក្ខជនថាបានចុះឈ្មោះបោះឆ្នោតក៏ដោយ។

[៣] តួលេខគិតពីថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៨ ដល់ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៨។

[៤] ការផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលក្នុងនោះអនុប្រធានគណបក្សប្រជាជនកម្ពុជា សម្តេច ហ៊ុន សែន បានមានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជាបានទទួល និងបន្តទទួលយកបេក្ខជន និងសមាជិកគណបក្សផ្សេងៗទៀតដែលចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។

លើសពីនេះទៅទៀត **មានការទំលាក់កំហុសគ្នាទៅវិញទៅមករវាងក្រុមប្រឹក្សាឃុំ/សង្កាត់ និងមន្ត្រី គ.ជ.ប** ចំពោះការបញ្ជាក់លើឈ្មោះបេក្ខជន។ មន្ត្រីក្រុមប្រឹក្សាឃុំ/សង្កាត់ ខ្លះបានអះអាងថា ខ្លួនចេញលិខិតបញ្ជាក់ឱ្យបេក្ខជន ដោយផ្អែកលើបញ្ជីឈ្មោះបោះឆ្នោតចាស់ ព្រោះ គ.ជ.ប មិនទាន់បញ្ជូនបញ្ជីឈ្មោះផ្លូវការចុងក្រោយមកឱ្យខ្លួននៅឡើយ ចំណែកឯមន្ត្រី គ.ជ.ប បានស្តីបន្ទោសថា មានមន្ត្រីក្រុមប្រឹក្សាឃុំ/សង្កាត់ខ្លះ មានការខ្វះចន្លោះច្រើន ដែលធ្វើឱ្យមានការបញ្ជាក់ខុស។ ប៉ុន្តែ គ.ជ.ប ត្រូវទទួលខុសត្រូវថា ហេតុអ្វីបានជាបាត់ឈ្មោះរបស់ពួកគេ**ចេញពីបញ្ជីឈ្មោះបោះឆ្នោត**ផ្លូវការ មានដូចជាករណីបេក្ខជនរបស់គណបក្ស**នរោត្តម រណឫទ្ធិ** គណបក្ស**ហ៊្វុនស៊ិនប៉ិច** គណបក្ស**សង្គមខ្មែរនិយម** ដែលឈ្មោះរបស់បេក្ខជនយ៉ាងហោចណាស់ ៤០ ត្រូវបានមន្ត្រី ឃុំ/សង្កាត់បញ្ជាក់ថា មានឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ប៉ុន្តែនៅពេលបញ្ជូនមក គ.ជ.ប ពិនិត្យរកឃើញថា ឈ្មោះទាំងនោះពុំមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការចុងក្រោយទេ ហើយបានតម្រូវឱ្យមន្ត្រី ឃុំ/សង្កាត់ ធ្វើការកែតម្រូវវិញ។ ឧទាហរណ៍ ករណីរបស់បេក្ខជនគណបក្សនរោត្តមរណឫទ្ធិ លោក **នរាណារិទ្ធ អានន្ទជាយាជ** ដែលឈ្មោះរបស់លោកមាននៅក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ ២០០៦ ក្នុងសង្កាត់ទូលទំពូង ២ លេខកូដការិយាល័យ ០៩៩៩ តែបែរជាមិនមានក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ ២០០៧ ទៅវិញ។

## ២. ឃាតកម្ម ការគំរាមកំហែង ការទម្លាក់ស្លាកគណបក្សនយោបាយ និងការរារាំងសកម្មភាពជួបប្រជុំ

ក្នុងដំណាក់កាលនៃការចុះបញ្ជីបេក្ខជន និងគណបក្សនយោបាយឈរឈ្មោះនេះ មាន**ករណីឃាតកម្មទៅលើសកម្មជនគណបក្សនយោបាយ**បានចាប់ផ្តើមកើតឡើងយ៉ាងតិចចំនួន **៣ ករណី**[5]។ ករណីឃាតកម្ម[6] កាលពីថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ ២០០៨ ទៅលើលោក **សុខ រុន** អាយុ ៤៧ ឆ្នាំដែល**ត្រូវបានគេសម្លាប់** គឺជាសកម្មជនរបស់គណបក្ស**នរោត្តមរណឫទ្ធិ** នៅឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

កាលពីថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ២០០៨ គណបក្ស**សិទ្ធិមនុស្ស** ក៏បានអះអាងដែរថា សកម្មជនរបស់ខ្លួនម្នាក់ដែលបានផ្តាច់ខ្លួនមកពីគណបក្សប្រជាជនកម្ពុជាឈ្មោះ **ឈួង សោម** នៅភូមិ តាអូ ឃុំតាអូ ស្រុក គីរីវង្ស ខេត្តតាកែវ **ត្រូវបានគេធ្វើឃាត** បន្ទាប់ពីមានជំលោះជាមួយអតីតមន្ត្រីប៉ូលីសម្នាក់។

គណបក្សមួយចំនួនបានត្អូញត្អែរថា **មានការគំរាមកំហែង បំភិតបំភ័យ និងការវាយដំ**រហូតដល់មានរបួសស្នាមទៅលើសកម្មជន និង**បេក្ខជនឈរឈ្មោះបោះឆ្នោត** ដូចជាករណី គណបក្សសមរង្ស៊ី បានអះអាងថា បេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ខ្លួនមួយរូប ឈ្មោះ **ប៊ិល ម៉េងឃាង** ដែលបច្ចុប្បន្នជាគ្រូបង្រៀន នៅសាលាបឋមសិក្សា សុខអានទទ្លាប់ នៅស្រុកគីរីវង្ស ខេត្តតាកែវ ត្រូវប្រធានការិយាល័យអប់រំស្រុកគីរីវង្ស ប្រើពាក្យសំដីគំរាមថា បើចង់ឈរជាបេក្ខជនឱ្យគណបក្ស សម រង្ស៊ី ពេលធ្វើច្បាប់សុំឈប់ពិសេសនេះរួច ពេលត្រឡប់មកវិញគាត់មិនធានាថាមានកន្លែងបង្រៀននៅសាលានេះដដែលទេ។

---

[5] គិតចាប់ពីថ្ងៃទី ២១ ខែ មីនា ដល់ ២១ ខែ ឧសភា ឆ្នាំ ២០០៨ (ការសង្កេតរបស់ខុមហ្វ្រែល និងរបាយការណ៍របស់អង្គការសិទ្ធិមនុស្ស អាដហុក)

[6] យោងតាមការអះអាងរបស់សមាគមការពារសិទ្ធិមនុស្សអាដហុក។

មានករណីចោទប្រកាន់ថា មានការវាយដំទៅលើបុរសម្នាក់ឈ្មោះ ហែម ពៅ ពីសំណាក់មេភូមិគណបក្សប្រជាជនកម្ពុជា ឈ្មោះ នូវ ណើយ ដោយសារតែខ្លួនបដិសេធបន្តគាំទ្រគណបក្សប្រជាជនកម្ពុជា។ ករណីនេះកើតឡើងនៅភូមិបន្ទាយឆ្មារខាងត្បូង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០០៨។ គណបក្សនរោត្តមរណឫទ្ធិ បានអះអាងថា សកម្មជនរបស់ខ្លួនមួយរូបឈ្មោះ អ៊ូច ផុន នៅស្រុកបាទី ខេត្តតាកែវ ត្រូវបានអង្គរក្ស ១០ នាក់ របស់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលម្នាក់វាយដំឱ្យមានរបួសស្នាមយ៉ាងធ្ងន់ធ្ងរកាលពីថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៨។

ក្រៅពីករណីខាងលើនេះ គណបក្សនយោបាយមួយចំនួនក៏បន្តជួបការលំបាកក្នុងការធ្វើសកម្មភាពនយោបាយ។ មានករណីទម្លាក់ផ្លាកគណបក្សនយោបាយមួយចំនួនបានកើតឡើងផងដែរនៅក្នុងខេត្តព្រៃវែង តាកែវ ពោធិ៍សាត់ ដូចជាករណីទម្លាក់ស្លាករបស់ គណបក្សនរោត្តមរណឫទ្ធិ យ៉ាងតិចចំនួន ៣ ករណី គណបក្សសម រង្ស៊ី យ៉ាងតិចចំនួន ២ ករណី និងមានការរារាំងរំខានពីសំណាក់អាជ្ញាធរមូលដ្ឋានទៅលើការជួបប្រជុំ។ ជាក់ស្តែង ការជួបប្រជុំរបស់គណបក្សនរោត្តមរណឫទ្ធិមួយ កាលពីថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានអជ្ញាធរសង្កាត់វាលវង់ នៅទីក្រុងភ្នំពេញ បានព្យាយាមបញ្ឈប់ ដោយលើកហេតុថា ជាការជួបប្រជុំនយោបាយខុសច្បាប់ ហើយតម្រូវឱ្យមានការសុំច្បាប់ពីសំណាក់អាជ្ញាធរក្រុងជាមុនសិន។ នៅព្រះរាជាណាចក្រកម្ពុជា គេពុំឃើញមានច្បាប់ណាមួយចែងឱ្យមានការសុំច្បាប់ពីសំណាក់អាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើសកម្មភាពជួបប្រជុំនយោបាយឡើយ។

## គ. មូលហេតុខ្លះចំពោះការថយចុះនូវចំនួនគណបក្សនយោបាយ :

មានមតិ និងនិន្នាការខ្លះពន្យល់ថា ការចូលរួមរបស់គណបក្សនយោបាយនៅក្នុងការបោះឆ្នោតនៅកម្ពុជាមិនគួរឱ្យមានគណបក្សច្រើនទេ។ លទ្ធភាព និងគុណភាពគណបក្សនយោបាយច្រើនចូលរួមការបោះឆ្នោត គឺមិនគ្រប់គ្រាន់ និងម្យ៉ាងទៀតក៏ធ្វើឱ្យអ្នកបោះឆ្នោតច្របូកច្របល់ក្នុងការជ្រើសរើស ដែលនាំឱ្យបំបែកសំលេងគណបក្សមិនកាន់អំណាច (គណបក្ស ប្រឆាំង)។ ប៉ុន្តែមតិនេះមិនបានពិនិត្យឱ្យស៊ីជំរៅទៅលើប្រព័ន្ធនយោបាយ និងដំណើរការបោះឆ្នោតនៅកម្ពុជា តាំងពីការជ្រើសរើស រដ្ឋសភា ព្រឹទ្ធសភា រហូតដល់ខេត្ត/ក្រុង សុក/ខណ្ឌ និងឃុំ/សង្កាត់ គឺបានប្រើប្រាស់ប្រព័ន្ធបញ្ជីគណបក្សនយោបាយ (ឬប្រព័ន្ធសមាមាត្រ) ដែលផ្តល់ឱ្យអំណោចគណបក្សនយោបាយក្នុងការសំរេចចិត្តពីថ្នាក់លើក្នុងការជ្រើសរើសបេក្ខជនដាក់ចូលក្នុងបញ្ជី និងត្រួតត្រារចនាសម្ព័ន្ធរដ្ឋទាំងនេះ។ ប្រជាពលរដ្ឋ និងអ្នកបោះឆ្នោតគ្មានសិទ្ធិអំណាចក្នុងការជ្រើសរើសអ្នកនយោបាយជាបុគ្គល ដែលខ្លួនពេញចិត្ត។ ប្រព័ន្ធនេះស្របជាមួយរដ្ឋធម្មនុញ្ញ ដែលជំរុញឱ្យមានពហុបក្សក្នុងអភិក្រម ប្រជាធិបតេយ្យ ប៉ុន្តែ មិនលើកទឹកចិត្តឱ្យមានពហុឯកត្តនាមច្រើនទេ។ ដូចនេះប្រព័ន្ធនេះត្រូវការឱ្យមានគណបក្សចូលរួមច្រើន មិនត្រឹមតែបានចុះឈ្មោះនៅក្រសួងមហាផ្ទៃទេ ប៉ុន្តែពួកគេត្រូវមានលទ្ធភាព និងឱកាសចូលរួមក្នុងដំណើរការបោះឆ្នោត។

បញ្ហាដែលមិនបង្កឱ្យគណបក្សនយោបាយតូចៗទទួលបានអាសនៈដូចការបោះឆ្នោត ១៩៩៣ នោះអាចមកពីការផ្លាស់ប្តូរច្បាប់បោះឆ្នោតទាក់ទិនប្រព័ន្ធបោះឆ្នោតសមាមាត្រជាមួយរូបមន្តគណនាអាសនៈមធ្យមភាគខ្ពស់បំផុត។ រូបមន្តនេះ មិនផ្តល់ឱកាសដល់គណបក្សតូចៗទទួលបានអាសនៈនៅសល់ទេ។ មិនដូចរូបមន្តគណនាអាសនៈក្នុងសម័យបោះឆ្នោត UNTAC ឆ្នាំ ១៩៩៣ ដែលយ៉ាងហោចមានគណបក្សតូចទទួលបានអាសនៈនៅសល់ ដូចជាគណបក្ស មូលីការ បានមួយអាសនៈនៅសល់។ ជាក់ស្តែងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៨ ឆ្នាំ២០០៣ គឺមានតែគណបក្សធំៗ ៣ ប៉ុណ្ណោះដែលបានទទួលសំលេងគាំទ្រ ហើយទទួលបានអាសនៈនៅក្នុងសភា។ នៅឆ្នាំ ២០០៣ គណបក្ស ប្រជាជនកម្ពុជា បានការគាំទ្រអ្នកបោះឆ្នោត ៤៧% ហើយគណនាជាអាសនៈបាន ៥៩% ដែលនេះមានន័យថា គណបក្សបានសន្លឹកឆ្នោតច្រើនមានលទ្ធភាពស្រូបយកបន្ថែមអាសនៈនៅសល់។

គណបក្សតូចៗជួបបញ្ហាថវិកាផងដែរ ផ្ទុយពីគណបក្សកាន់អំណាចមានធនធានដ៏ច្រើនដែលមិនអាចត្រួតពិនិត្យ ដែលត្រូវចំណាយទៅលើការបង់ថវិកាតំកល់ដែលកើនឡើងពីដប់លាន (១០.០០០.០០០) រៀល ទៅដប់ប្រាំលាន (១៥.០០០.០០០) រៀល (វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាំងពីឆ្នាំ ២០០៣[៧]) និងការឃោសនា។ បើគណបក្សទាំងនោះមិនបានអាសនៈ ឬទទួលបានសន្លឹកឆ្នោតយ៉ាងតិច ៣% នៃសន្លឹកឆ្នោតបានការ នោះថវិកាតំកល់នឹង មិនត្រូវបានបង្វិលឱ្យគណបក្សវិញទេ។ ក្នុងលក្ខខណ្ឌនេះ វាមានន័យ ថាគណបក្សតូចៗខិតខំដាក់បញ្ជីគណបក្សនៅស្ទើរ គ្រប់មណ្ឌលខេត្ត/ក្រុង ដើម្បីសន្សំ និងប្រមូលសន្លឹកឆ្នោត បើទោះបីជាគណបក្សនោះមិនសង្ឃឹមទទួលបានអាសនៈនៅក្នុង មណ្ឌលខេត្ត/ក្រុងមួយចំនួន ឬខ្វះធនធានយ៉ាងណាក៏ដោយ។ រដ្ឋគ្មានថវិកាជាតិដើម្បីជួយគាំទ្រគណបក្សទាំងនោះទេ។

ក្នុងចំណោមគណបក្ស ដែលបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៨ ទាំង៣៩ មានគណបក្សចំនួន ០៤ ដែលដឹកនាំដោយស្ត្រី ឆ្នាំ២០០៣ មានគណបក្សចំនួន០២ប៉ុណ្ណោះ ដោយឡែកឆ្នាំ២០០៨នេះ ពុំមានគណបក្សដែលដឹកនាំដោយស្ត្រីទេ។ ហើយក្នុងចំណោមគណបក្សទាំង ២៣ ដែលបានចូលរួមបោះឆ្នោតនៅឆ្នាំ ២០០៣ មានគណបក្សតែ ៥ ប៉ុណ្ណោះ ដែលបានបន្តចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ នេះទៀត ហើយគណបក្សដែលទើបចូលរួមថ្មីចំនួន ៧នោះ គឺគណបក្ស នរោត្តមរណឫទ្ធិ គណបក្សសិទ្ធិមនុស្ស គណបក្សសង្គមយុត្តិធម៌ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សខ្មែរឈប់ក្រ គណបក្សខ្មែរសាធារណរដ្ឋ និង គណបក្សសង្គមខ្មែរនិយម។ គួរកត់សម្គាល់ថា គណបក្សនរោត្តមរណឫទ្ធិ គឺត្រូវបានធ្វើសមាជប្តូរឈ្មោះមកពីគណបក្សរណសិរ្សជនជាតិខ្មែរ ដែលធ្លាប់ចូលរួមប្រកួតការបោះឆ្នោតឆ្នាំ ២០០៣ ផងដែរ។ ដោយឡែកគណបក្ស សិទ្ធិមនុស្ស ជាគណបក្សចុះឈ្មោះថ្មីក៏ដោយ ក៏ប៉ុន្តែគណបក្សនេះ មានការចូលរួមគាំទ្រពីគណបក្សចាស់ៗ ដូចជាគណបក្សទ្រទ្រង់ជាតិកម្ពុជា គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ។

[៧] វិសោធនកម្មនៅ ឆ្នាំ ២០០២

## ឃ. ការធ្លាក់ចុះចំនួនបេក្ខនារី

បើយោងតាមតួលេខបណ្ដោះអាសន្នរបស់ គ.ជ.ប បានបង្ហាញឱ្យឃើញថា ចំនួនបេក្ខនារីឈរឈ្មោះ មានការធ្លាក់ចុះពាក់កណ្ដាលបើប្រៀបធៀបនឹងការបោះឆ្នោតលើកមុនៗ និងមិនបានទៅដល់សំណើយ៉ាងតិច ៣០%។ តួលេខបេក្ខនារីពេញសិទ្ធិសរុបទាំង ១២ គណបក្សគឺមានត្រឹមតែ ១៤% ប៉ុណ្ណោះ ធ្លាក់ចុះពី ២៧% ក្នុងឆ្នាំ ២០០៣ រីឯឆ្នាំ ១៩៩៨ មាន ១៧%។ តួលេខនេះ អាចបញ្ជាក់ថា ជារួម គណបក្សនយោបាយថ្មីៗភាគច្រើនដែលចូលរួមប្រកួតប្រជែងការបោះឆ្នោត មិនដាក់បញ្ចូលស្ត្រីទៅក្នុងបញ្ជីឈ្មោះបេក្ខជនច្រើនទេ។ បើពិនិត្យដោយឡែក គណបក្សដែលមានអាសនៈក្នុងសភាសំខាន់ពីរបានខិតខំបញ្ចូលចំនួនបេក្ខនារីពេញសិទ្ធិទៅក្នុងបញ្ជីបេក្ខជនកើនឡើង ដូចជាគណបក្ស ប្រជាជនកម្ពុជា មាន ២០ រូប ស្មើនឹង ១៦% (កើនពី ១៤ រូប នៅឆ្នាំ ២០០៣) គណបក្សសម រង្ស៊ី ១៧ រូប ស្មើនឹង ១៤% (កើនពី ១៤ រូប នៅឆ្នាំ ២០០៣)។ ដោយឡែកគណបក្សហ្វ៊ុនស៊ិនប៉ិចមាន ១០ រូប ស្មើនឹង ៨% (ថយពី ១៤ រូប នៅឆ្នាំ ២០០៣) ប៉ុន្តែបានដាក់ស្ត្រីជាបេក្ខជននាយករដ្ឋមន្ត្រី។

ចំណែកឯ គណបក្សនរោត្តម រណប្ញទ្ធិ មាន ១១ រូបជាបេក្ខនារីពេញសិទ្ធ ស្មើនឹង ៩% គណបក្សសិទ្ធិមនុស្ស មាន ១១ រូប ស្មើនឹង ៩%។ គណបក្សនយោបាយដែលដាក់បេក្ខនារីច្រើនជាងគេ គឺគណបក្សប្រជាធិបតេយ្យខ្មែរ ដែលបានខិតខំដាក់ បេក្ខនារីរហូតដល់ ៣០ រូប ដែល ស្មើនឹង ២៤% បន្ទាប់មកគឺ គណបក្សសង្គមយុត្តិធម៌ មាន ១៨ រូប (៧ ខេត្ត/ក្រុង) ស្មើនឹង ៣៩% និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ មាន ២៤ រូប ដែល ស្មើនឹង ២០%។

ជាសរុប ភាពមិនប្រក្រតីនៃការចុះឈ្មោះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតបណ្ដាលមកពីបញ្ហានៃបញ្ជីបោះឆ្នោត ពិសេសការធ្វើបច្ចុប្បន្នភាព និងការសម្អាតបញ្ជីបោះឆ្នោត។

ម្យ៉ាងទៀត ការធ្លាក់ចុះនៃការចូលរួមរបស់គណបក្សនយោបាយមានការទាក់ទងទៅនឹងក្របខណ្ឌច្បាប់បោះ-ឆ្នោត ដែលប្រើរូបមន្តមធ្យមភាគខ្ពស់បំផុត លក្ខខណ្ឌនៃការទទួលបានលុយតំកល់មកវិញ និងគ្មានគោលនយោបាយ ឬក្របខណ្ឌច្បាប់ ជាពិសេសដែលត្រូវផ្ដល់ថវិកាគាំទ្រគណបក្សនយោបាយក្នុងការធ្វើសកម្មភាព និងឃោសនាបោះឆ្នោត។ ការធ្លាក់ចុះចំនួនបេក្ខនារីក្នុងបញ្ជីគណបក្សនយោបាយអាចបណ្ដាលមកពីការសម្រឹមតែទៅលើឆន្ទៈថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ ប៉ុន្តែគ្មានគោលនយោបាយច្បាស់លាស់ និងមានការគិត និងវិនិច្ឆ័យជាមុនថា ស្ត្រីខ្វះសមត្ថភាពជាងបុរសក្នុងកិច្ចការនយោបាយ។

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១
- លោក **កុយ ចំនួនដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** មន្ត្រីផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០៩២ ៨៦២ ៦០២